**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល**
**(ខេមបូឌា) ភីអិលស៊ី**

*ថ្ងៃសុក្រ ៨ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការពន្យារពេលក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣
## របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ដោយសារមូលហេតុដូចមានរៀបរាប់ខាងក្រោមនេះ ក្រុមហ៊ុនសូមពន្យាពេលបង្ហាញជូនរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ និងផ្តល់ជូនរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ ២០២៣ នេះ ជូនវិនិយោគិន និងសាធារណជន យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ ៖

១- ដោយសារក្រុមហ៊ុនមានការដំឡើងប្រព័ន្ធគ្រប់គ្រងសន្និធិថ្មីទៅលើការទិញវត្ថុធាតុដើម និងត្រូវចំណាយពេលក្នុងការសិក្សាទៅលើមុខងារនៃការប្រើប្រាស់នីមួយៗក្នុងការផ្ទៀងផ្ទាត់បញ្ជីសន្និធិ ដែលធ្វើអោយមានការយឺតយ៉ាវក្នុងការបិទបញ្ជីគណនេយ្យសម្រាប់ដំណើរការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រា ដោយក្រុមហ៊ុនសវនកម្មឯករាជ្យរបស់ក្រុមហ៊ុន។

២- ក្នុងអំឡុងពេលបិទបញ្ជីគណនេយ្យនេះ ក្រុមហ៊ុនមានការឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ មួយសប្តាហ៍ ក្នុងខែមេសា កន្លងទៅនេះ។

អាស្រ័យដូចមានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:២៣ ៨៩០ ៣២៥(៨៥៥) /ទូរសារ :២៣ ៨៩០ ៣២៦(៨៥៥) / គេហទំព័រ : www.Grandtwins.com.kh/អ៊ីម៉ែល : vuthy.phuong@qmico.com